## ជូនចំពោះអតិថិជនធនាគារ Shinkin Banks

# សូមលោកអ្នកយល់ និងសហការចំពោះការបញ្ជាក់ទៀងទាត់អំពី “ព័ត៌មានអតិថិជន”

-សូមសហការក្នុងការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ និងហិរញ្ញប្បទានភេរវកម្ម-

ពេលថ្មីៗនេះ ការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ និងហិរញ្ញប្បទានភេរវកម្ម មានសារៈសំខាន់កាន់តែខ្លាំងឡើងៗក្នុងសង្គមអន្តរជាតិ។ ឧក្រិដ្ឋកម្មហិរញ្ញវត្ថុក៏កំពុងកើនឡើងផងដែរនៅក្នុងប្រទេសជប៉ុន ដូចជាការឆបោកពិសេសយកគណនីបញ្ញើទៅប្រើក្នុងគោលបំណងឧក្រិដ្ឋ។

គ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗបានចាត់វិធានការផ្សេងៗដោយផ្អែកលើច្បាប់ស្តីពីការបង្ការការផ្ទេរប្រាក់ឧក្រិដ្ឋកម្ម និង "សេចក្តីណែនាំអំពីវិធានការប្រឆាំងនឹងការលាងលុយកខ្វក់ និងការប្រយុទ្ធប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្ម” របស់ទីភ្នាក់ងារសេវាកម្មហិរញ្ញវត្ថុ ដើម្បីឱ្យលោកអ្នកអាចប្រតិបត្តិការប្រកបដោយសុវត្ថិភាពនិងគ្មានការបារម្ភ។

ក្នុងចំណោមវិធានការទាំងនោះ **គ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ រួមទាំងធនាគារ Shinkin Banks បានធ្វើសកម្មភាពបញ្ជាក់នូវបច្ចុប្បន្នភាពនៃព័ត៌មានអតិថិជនឱ្យបានទៀងទាត់ (*)។**

(*) គឺជាវិធានការរបស់គ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ ក្នុងការបញ្ជាក់ឱ្យបានទៀងទាត់នូវព័ត៌មានអតិថិជន និងគោលបំណងនៃប្រតិបត្តិការ ជាដើម ទៅតាមខ្លឹមសារនិងស្ថានភាពនៃប្រតិបត្តិការរបស់លោកអ្នក។

ការបញ្ជាក់ទៀងទាត់អំពីព័ត៌មានរបស់អតិថិជនបែបនេះ គឺមានគោលបំណងការពារកុំឱ្យអង្គភាពឧក្រិដ្ឋកម្ម ឬភេរវកម្មប្រើប្រាស់ស្ថាប័នហិរញ្ញវត្ថុមិនត្រឹមត្រូវដោយបង្កប់ខ្លួនក្នុងចំណោមអតិថិជនស្មោះត្រង់ ដោយមិនដឹងខ្លួន ឬការពារកុំឱ្យគេប្រើគណនីធនាគាររបស់អតិថិជន ដោយក្លែងបន្លំប្រើឈ្មោះអ្នកនោះ ដើម្បីឱ្យលោកអ្នកដែលជាអតិថិជនអាចប្រើស្ថាប័នហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាពនិងគ្មានការបារម្ភ។

សូមលោកអ្នកយល់ ហើយ**សហការចំពោះការបញ្ជាក់ទៀងទាត់អំពី “ព័ត៌មានអតិថិជន”នេះ ពីធនាគារ Shinkin Banks យើងខ្ញុំ។**

ពេលថ្មីៗ នេះ ការឆបោកយកព័ត៌មានរបស់អតិថិជនតាមវិធីផ្សេងៗបានកើតមានឡើងយ៉ាងច្រើន ហេតុនេះហើយ ក្នុងករណីដែលមានការមន្ទិលសង្ស័យអ្វីមួយ សូមលោកអ្នកទាក់ទងសួរទៅទីស្នាក់ការកណ្តាល ឬសាខានៃធនាគារ Shinkin Banks ដែលលោកអ្នកប្រតិបត្តិការជាមួយ។

Face to Face 一般社団法人 全国信用金庫協会 The National Association of Shinkin Banks

金融庁 Financial Services Agency